Ministry of Foreign Affairs and
International Cooperation
Kingdom of Cambodia
OFFICE OF THE SPOKESPERSON

# បច្ចុប្បន្នភាពស្ដីពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ
# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥

## I. ករណីឧបទ្ទវហេតុនៅភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ៖

- **រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនចេញសេចក្តីប្រកាសបដិសេធព័ត៌មាន– ប្រកាសបដិសេធ និងច្រានចោលទាំងស្រុង ចំពោះព័ត៌មានមិនពិត ក្លែងក្លាយ ដែលគណនី Facebook Page មានឈ្មោះ "Royal Thai Army: Update" ដែលបានបង្ហោះផ្សាយ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥៖**

  - នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ **រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន** បានចេញសេចក្តីប្រកាសបដិសេធព័ត៌មានរបស់គណនី Facebook Page ឈ្មោះ "Royal Thai Army: Update" ដែលបានបង្ហោះផ្សាយព័ត៌មាន កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០២៥ ដោយប្រើប្រាស់ប្លង់បង្ហាញលក្ខណៈភូមិសាស្ត្រ និងទីតាំងបង្គោលព្រំដែន ដែលនាំឱ្យមានការភាន់ច្រឡំអំពីទីតាំងពិតប្រាកដនៃបង្គោលព្រំដែនលេខ ៤២ និងលេខ ៤៣ នៅតំបន់ភូមិព្រៃចាន់។

  - **រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន** បានច្រានចោលទាំងស្រុងនូវ "***ការផ្សព្វផ្សាយព័ត៌មានមិនពិត គ្មានវិជ្ជាជីវៈ និងមានចេតនាទុច្ចរិត ដែលបានប្រើប្រាស់ឯកសារ និងព័ត៌មានប្រាស់ចាកពីការពិត ក្នុងចេតនាបំភាន់សាធារណជនជាតិ និងអន្តរជាតិឱ្យមានការភាន់ច្រឡំ។***"

  - ទន្ទឹមនេះ **រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន** បានផ្តល់ការស្រាយបំភ្លឺជូនសាធារណជននូវចំណុច ដូចខាងក្រោម៖

    "១. ឯកសារដែលបានបង្ហាញក្នុងគណនីខាងលើនេះ គឺជាប្លង់បង្ហាញលក្ខណៈភូមិសាស្ត្រ និងទីតាំងបង្គោលព្រំដែន ដែលជាឧបសម្ព័ន្ធនៃកំណត់ហេតុ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និងឧបសម្ព័ន្ធនៃកំណត់ហេតុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រុមវាស់វែងចម្រុះកម្ពុជា-ថៃ ស្តីពីលទ្ធផលនៃការរុករកទីតាំងពិតប្រាកដនៃបង្គោលព្រំដែនលេខ៤២ និងលេខ៤៣ ដែលបានបោះនាសម័យបារាំងប៉ុណ្ណោះ ***ហើយពុំមែនជាផែនទី ឬជាឯកសារដែលបញ្ជាក់ពី ខ្សែព្រំដែនឡើយ។***

២. ម្ចាស់គណនី Facebook Page ខាងលើនេះ បានយកទិន្នន័យនៅក្នុងប្លង់បង្ហាញលក្ខណៈ ភូមិសាស្ត្រ និងទីតាំងបង្គោលព្រំដែនខាងលើ *មកគូសក្លែងបន្លំជាខ្សែព្រំដែននៅលើផែនទី រូបភាពផ្កាយរណប ដើម្បីបំភាន់សាធារណជនជាតិ និងអន្តរជាតិឱ្យមានការភាន់ច្រឡំថា ខ្សែព្រំដែនដែលខ្លួនបានគូសក្លែងបន្លំនេះ ជាខ្សែព្រំដែនដែលបានឯកភាពដោយក្រុមកាស់វែងចម្រុះកម្ពុជា-ថៃ*។

៣. *តំបន់ភូមិព្រៃចាន់ ដែលស្ថិតនៅចន្លោះបង្គោលព្រំដែនលេខ ៤២ និង ៤៣ គឺជាតំបន់ ដែលភាគីទាំងពីរ ពុំទាន់បានឯកភាពគ្នាខណ្ឌសីមានៅលើដីជាក់ស្តែងនៅឡើយ* ហើយកិច្ចការនេះ ត្រូវដោះស្រាយដោយគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) កម្ពុជា-ថៃ និងគ្មានយន្តការ ឬស្ថាប័នណាមួយមានសមត្ថកិច្ចលើកិច្ចការនេះឡើយ។"

**II.** នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភាកម្ពុជា បានជួបនិងពិភាក្សាការងារជាមួយ **ឯកឧត្តម វ៉ូកធឺ បេកគី** (Wouter Beke) ប្រធានគណៈប្រតិភូសភាអឺរ៉ុប និងជាសមាជិកសភាអឺរ៉ុប នៅក្នុងឱកាសចូលរួមមហាសន្និបាតអាយប៉ាលើកទី៤, ទីក្រុងគូឡាឡាំពួ –

- ពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភាកម្ពុជា បានធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសភាអឺរ៉ុប ដែលបានចេញសម្តែងការគាំទ្រតាមរយៈការចេញនូវសេចក្តីថ្លែងការណ៍គាំទ្រកិច្ចព្រមព្រៀងបទឈប់បាញ់កម្ពុជា-ថៃ និងបានតាមដានដោយយកចិត្តទុកដាក់លើការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់ ចាប់តាំងពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ មក។

- **ឯកឧត្តម វ៉ូកធឺ បេកគី** (Wouter Beke) បានបង្ហាញនូវចំណាប់អារម្មណ៍ជាខ្លាំងចំពោះការវិវត្តចុងក្រោយនៃជម្លោះព្រំដែនកម្ពុជា-ថៃ ព្រមទាំងបានបញ្ជាក់ថា សហភាពអឺរ៉ុបបាននិងកំពុងបន្តតាមដានស្ថានការណ៍យ៉ាងយកចិត្តទុកដាក់ ហើយបានជំរុញឱ្យមានការអនុវត្តបទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព ដើម្បីធានានូវសន្តិភាពយូរអង្វែងរវាងប្រទេសជិតខាងទាំងពីរ។

**III.** គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥ ជា**ថ្ងៃទី ៥៤ហើយ** ដែល**វីរកងទ័ពកម្ពុជាចំនួន ១៨ រូប** ត្រូវបានចាប់ឃុំខ្លួនដោយយោធាថៃ ក្រោយបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ កម្ពុជាអំពាវនាវឱ្យភាគីថៃ ដោះលែងកងទ័ពកម្ពុជាទាំង ១៨រូប ប្រកបដោយសុខសុវត្ថិភាព ស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ។

**Ministry of Foreign Affairs and**
**International Cooperation**
**Kingdom of Cambodia**
**OFFICE OF THE SPOKESPERSON**

## Updates on the situation of the Cambodia-Thailand border
## 21 September 2025

I. **On the incident at Prey Chan village, O Bei Choan commune, O Chrov district, Banteay Meanchey province:**

- **Press Statement by the State Secretariat of Border Affairs (SSBA)— strongly rejects and condemns the false and fabricated information posted by the Facebook Page named "Royal Thai Army: Update" on September 19, 2025:**
    - On September 20, 2025, the SSBA issued a press statement to reject false information posted on the Facebook Page named **"Royal Thai Army: Update"** on September 19, 2025. The Facebook page displayed terrain and locations, causing misunderstanding and confusion about the exact locations of the Boundary Pillar No. 42 and No. 43 in the Prey Chan area.
    - The SSBA expressed that "this false, unprofessional and malicious information, which has misused documents and distorted facts **with the clear intention of misleading both national and international public opinion."**
    - The SSBA's statement clarified the following points:

        "1. The documents shown in the aforementioned Facebook Page are merely Field Plan Showing the Terrain and Exact Location of Boundary Pillar, which are annexes the Report of the Results dated 24 November 2017 and 28 December 2016, prepared by the Cambodia-Thailand Joint Survey Team regarding the Results of the Fact-Finding Mission on the Condition and Location of Boundary Pillar No. 42 and No. 43, which were installed during the French colonial period. **These are not official maps or documents that define the boundary line.**

2. The administrator of the aforementioned Facebook Page used data from these Field Plan Showing the Terrain and Exact Location of the Boundary Pillar **to falsely produce a boundary line on satellite image, with [the] intent to mislead the national and international public into believing that this fabricated boundary line was the official one agreed by the Cambodia-Thailand Joint Survey Teams.**

3. **The Prey Chan area, located between Boundary Pillar No. 42 and No. 43, is a region where both parties have not yet reached any mutual agreement to demarcate the boundary on the ground.** This matter must be resolved by the Cambodia-Thailand Joint Boundary Commission (JBC), and no other mechanism or institution has the mandate over this issue."

II. **On September 20, 2025, Samdech Maha Rathsapheathika Thipadei Khuon Sudary had a meeting discussion with H.E. Wouter Beke, Head of the European Parliament Delegation and Member of the European Parliament, on the sidelines of the AIPA-46, Kuala Lumpur—**

- Regarding the situation of the border issue between Cambodia and Thailand, **Samdech Khuon Sudary** expressed deep gratitude to the European Parliament for its consistent support, particularly for issuing statements calling for the Cambodia–Thailand ceasefire and for closely monitoring its implementation since the agreement took effect on 28 July 2025.
- **H.E. Wouter Beke** expressed interest in the latest developments in the Cambodia–Thailand conflict, noting that the European Union has been following the situation closely and encourages the effective implementation of the ceasefire, with the aim of ensuring lasting peace and stability between Cambodia and Thailand.

III. As of September 21, 2025, it has been **54 days** since **18 Cambodian soldiers** were captured under captivity of the Thai military. Cambodia urgently calls on the Thai side to release them as soon as possible, in accordance with international humanitarian law.